# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៨ ខែមិនា ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៩៣,៧០០ ដុល្លារអាមេរិក សម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពត្នោតពងក្នុងខេត្តបាត់ដំបង



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុនជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ)រដ្ឋាភិបាលជប៉ុននឹងផ្តល់ទឹកប្រាក់សរុបចំនួន៩៣,៧០០ដុល្លារអាមេរិកដល់មន្ទីរធនធានទឹកនិងឧតុនិយមខេត្តបាត់ដំបងសម្រាប់គម្រោងស្តារប្រព័ន្ធស្រោចស្រពត្នោតពងខេត្តបាត់ដំបង។កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាដោយលោក តាស៊ុយ៉ាម៉ាជីដា  ទីប្រឹក្សាស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជានិងលោក ឡុង ផលគុណ ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបងនៅស្ថានទូតជប៉ុន។



ជាមួយនឹងជំនួយនេះប្រព័ន្ធស្រោចស្រពត្នោតពងនឹងត្រូវបានជួសជុលដោយមន្ទីរធនធានទឹកនិងឧតុនិយមខេត្តបាត់ដំបង។គម្រោងនេះរួមបញ្ចូលការស្តារប្រឡាយកម្រិតបីមួយខ្សែ និងការសាងសង់សំណង់ទម្លាក់ទឹក។ យើងរំពឹងថា វានឹងកាត់បន្ថយផលប៉ះពាល់ពីទឹកជំនន់ដែលកើតមានឡើងជារៀងរាល់ឆ្នាំ និងសម្រួលដល់ការងារស្រោចស្រពរបស់ប្រជាកសិករប្រមាណ៣,១៨៨គ្រួសារនៅក្នុងតំបន់។ ដោយមានជំនួយផ្នែកបច្ចេកទេសពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង ប្រជាសហគមន៍នឹងថែទាំប្រព័ន្ធស្រោចស្រពនេះឲ្យមានសភាពល្អជានិច្ច។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណិ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជាភាពក្រីក្រនិងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបាន

ផ្តល់ថវិកាជាង៤៧.៥លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៤៧៣គម្រោងនៅទូទាំងប្រទេស។



---


*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*